ជស / រកម / ០៧៩៩ / ០៧

# ព្រះរាជក្រម

## យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់-តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការទូទាត់ថវិកា ទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គ លើកទី១ នីតិកាលទី១ ហើយដែលមានសេចក្តី ទាំងស្រុង ដូចតទៅ :

# ច្បាប់

# ស្តីពី

# ការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់
# ការគ្រប់គ្រងឆ្នាំ ១៩៩៧

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានយល់ព្រមតាមការអនុវត្តនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម១២៩៦/៣៧ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៦ ។ ការអនុវត្តនេះលេចចេញជាលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោមនេះ ÷

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូល ចំណាយនៃការគ្រប់គ្រងឆ្នាំ ១៩៩៧ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ ១៩៩៧ | ច្បាប់ទូទាត់ថវិកាឆ្នាំ ១៩៩៧ |
|---|---|---|
| សរុបចំណូល [1] | ១ ៤៩៦ ៩០០ | ១ ៣៦០ ៧១៤ |
| សរុបចំណាយ | ១ ៤៩៦ ៩០០ | ១ ២៧៣ ៦៧១ |
| ចំនួនលើសនៃតុល្យភាពរវាងចំណូលចំណាយ | - | ៤៧ ០៤៣ |
| កិច្ចប្រតិបត្តិការនៃច្បាប់ហិរញ្ញវត្ថុដែលបានអនុវត្តដោយរតនាគារជាតិ | | |
| ចំណូលថវិកា | ១ ០០៨ ៩០០ | ៩៧៩ ០៩៧ |
| . ចំណូលក្នុងប្រទេសជាប្រចាំ | ៨៨៥ ០០០ | ៨៦៨ ៦៧២ |
| . ចំណូលក្នុងប្រទេសជាមូលធន | ១២ ១០០ | ១២ ៣៣៤ |
| . ចំណូលក្រៅប្រទេសជាមូលធន | ១១១ ៨០០ | ៩៨ ០៩០ |
| ចំណាយថវិកា | ១ ០០៨ ៩០០ | ៩៣២ ០៥៤ |
| . ចំណាយជាប្រចាំ | ៨៧០ ០០០ | ៨១៤ ៩៨២ |
| . ចំណាយជាមូលធន | ១៣៨ ៩០០ | ១១៦ ០៧២ |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរតនាគារជាតិ | | |
| . ធនធានជាមូលធនសំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេស | ៤៨៨ ០០០ | ៣៨១ ៦១៧ |
| . ចំណាយជាមូលធនដោយធនធានសំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៤៨៨ ០០០ | ៣៨១ ៦១៧ |

[1] ក្នុងនោះមានវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលបានលើកឡើងនេះគ្រាន់ជាការបញ្ចូលបង្ហាញប៉ុណ្ណោះ ពីព្រោះកិច្ចប្រតិបត្តិការដែលបានអនុវត្តផ្ទាល់ដោយហិរញ្ញប្បទានក្រៅប្រទេស មិនឆ្លងកាត់រតនាគារជាតិ និងមិនបានចុះកិច្ចបញ្ជីកាតុល្យភាពក្នុងសេវនាវរតនាគារជាតិទេ កិច្ចប្រតិបត្តិការនេះគឺគ្រាន់តែជាការបាន់ប្រមាណដោយមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកផ្តល់មូលនិធិ ។

មាត្រា ២.-

ចំណូលថវិកាដែលបានអនុវត្តដោយរតនាគារជាតិ ត្រូវបានលំអិតតាមមាតិកា នៅក្នុងតារាង"ក" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយថវិកាដែលបានអនុវត្តដោយរតនាគារជាតិ ត្រូវបានលំអិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូកនៅក្នុងតារាង "ខ" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង "ខ១" ដែលភ្ជាប់មកជាមួយច្បាប់នេះគឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ដែលបានសំរេចក្នុងរយៈពេលនៃការគ្រប់គ្រងឆ្នាំ ១៩៩៧ និងដែលបានបែងចែកតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល ។

ការប៉ាន់ប្រមាណសំរេចបានស្តីពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកា និងចំពោះចំណាយត្រូវបានលំអិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល ហើយត្រូវបានបញ្ជាក់ជាបន្ទុបន្ទាប់នៅក្នុងតារាង "ក" និង "ខ" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង "ខ២" ដែលភ្ជាប់មកជាមួយច្បាប់នេះគឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្រៅរតនាគារជាតិ ដែលបានសំរេចក្នុងរយៈពេលនៃការគ្រប់គ្រងឆ្នាំ ១៩៩៧ និងត្រូវបានបែងចែកតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែលដោយអ្នកផ្តល់បរទេស ។

# ជំពូកទី ២

## បទបញ្ញត្តិ
## ស្តីពីកិច្ចប្រតិបត្តិការថវិកា

មាត្រា ៣.-

ការប្រមូលចំណូលជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទាន អាករ ផលិតផល និងផលទុន ព្រមទាំងការសំរេចបាននូវអំណោយមូលនិធិបដិភាគនិងធនធានដែលបានមកពីការខ្ចី ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ មានចំនួនទឹកប្រាក់សរុប................................................... ១ ០០៨ ៥០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់.................................................. ៩៧៩ ០៩៧ លានរៀល

ដូច្នេះមានចំណូលខ្វះចំនួន.................................................. -២៩ ៤០៣ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ ÷

| | | | |
|---|---|---|---|
| ចំណូលក្នុងប្រទេសជាប្រចាំ | - គំរោង.................................. | ៨៨៤ ០០០ | លានរៀល |
| | - ការសំរេចបាន.................................. | ៨៦៨ ៦៣២ | លានរៀល |
| | - មានចំនួនខ្វះ.................................. | -១៦ ៣៦៨ | លានរៀល |
| ចំណូលក្នុងប្រទេសជាមូលធន | - គំរោង.................................. | ១២ ១០០ | លានរៀល |
| | - ការសំរេចបាន.................................. | ១២ ៣៣៤ | លានរៀល |

- មានចំនួនលើស........................................២៣៩ លានរៀល

ចំណូលក្រៅប្រទេសជាមូលធន
- គំរោង........................................១១១ ៨០០ លានរៀល
- ការសំរេចបាន........................................៩៨ ០៩០ លានរៀល
- មានចំនួនខ្វះ........................................-១៣ ៣១០ លានរៀល

មាត្រា ៤.-

ចំណាយថវិកាទូទៅរបស់រដ្ឋដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ មានចំនួនទឹកប្រាក់សរុប........................................១ ០០៨ ៥០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់........................................៩៣២ ០៥៤ លានរៀល

ដូច្នេះមានការសន្សំសំចៃថវិកាបានចំនួន........................................-៧៦ ៤៤៦ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តដូចតទៅ ៖

ចំណាយជាប្រចាំ
- គំរោង........................................៨៧០ ០០០ លានរៀល
- ការសំរេចបាន........................................៨១៥ ៩៨២ លានរៀល
- មានការសន្សំសំចៃចំនួន........................................-៥៤ ០១៨ លានរៀល

ចំណាយជាមូលធននៃវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ៖
- គំរោង........................................១២២ ៨០០ លានរៀល
- ការសំរេចបាន........................................១១០ ៣២២ លានរៀល
- ដូច្នេះមានចំនួនខ្វះ........................................-១២ ៤៧៨ លានរៀល

ចំណាយជាមូលធននៃការវិលសងបំណុល ៖
- គំរោង........................................១៥ ៧០០ លានរៀល
- ការសំរេចបាន........................................៥ ៧៥០ លានរៀល
- ដូច្នេះមានការសន្សំសំចៃចំនួន........................................-៩ ៩៥០ លានរៀល

មាត្រា ៥.-

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយតាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ ដែលបានសំរេចដោយរតនាគារជាតិ ដូចមានបញ្ជាក់នៅក្នុងមាត្រា៣ និងមាត្រា៤ ខាងលើ បានបង្ហាញជាលទ្ធផលនូវចំណូលលើសចំណាយដូចតទៅ ៖

- ចំណូលថវិកាដែលបានសំរេចដោយរតនាគារជាតិសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ........................................៩៧៩ ០៩៧ លានរៀល
- ចំណាយថវិកាដែលបានសំរេចដោយរតនាគារជាតិសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ........................................៩៣២ ០៥៤ លានរៀល
- ចំនួនលើសនៃគណនេយ្យចំណូលលើសចំណាយ........................................៤៧ ០៤៣ លានរៀល

ចំនួនលើសនៃគណនេយ្យនេះគឺជាលទ្ធផលនៃ ៖

- ចំនួនលើសនៃចំណូលលើចំណាយជាប្រចាំ........................................(+) ៥២ ៦៩០ លានរៀល
- និងឱនភាពនៅក្នុងកិច្ចប្រតិបត្តិការជាមូលធន........................................(-) ៥ ៦៤៧ លានរៀល

ដោយអនុលោមទៅតាមបទប្បញ្ញត្តិក្នុងមាត្រា៩៧នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ០១ ន.ស.៩៣. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ចំនួនលើសនៃគណនេយ្យចំណូលលើសចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៧ មានចំនួនទឹកប្រាក់ ៤៧ ០៤៣ លានរៀល ត្រូវបានកត់ត្រាទៅក្នុងគណនីលទ្ធផលដែលបានបើកនៅក្នុងលេខនានៃធនាគារជាតិ ។

## ជំពូកទី ៣

## បទប្បញ្ញត្តិស្តីពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ផ្ទាល់ដែលបានអនុវត្តក្រៅធនាគារជាតិ

**មាត្រា ៦.-**

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលបានអនុវត្តក្រៅធនាគារជាតិនិងដែលបានគ្រោងទុកសរុបចំណូលស្មើនឹងសរុបចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ មានចំនួនទឹកប្រាក់........................................................................ ៤៨៨ ០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់........................................ ៣៤១ ៦១៧ លានរៀល

ដូច្នេះមានចំនួនខ្វះ: ........................................ - ១៤៦ ៣៨៣ លានរៀល

## ជំពូកទី ៤

## បទប្បញ្ញត្តិស្តីពី

## តុល្យភាពនៃហិរញ្ញវត្ថុសាធារណៈសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧

**មាត្រា ៧.-**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ត្រូវបានឆ្លុះបញ្ចាំងនូវ ÷

- កិច្ចប្រតិបត្តិការចំណូលថវិកាទូទៅរបស់រដ្ឋ (តារាង "ក") និងកិច្ចប្រតិបត្តិការចំណាយថវិកាទូទៅរបស់រដ្ឋ (តារាង "ខ")
- កិច្ចប្រតិបត្តិការនៃរតនាគារជាតិ
- ទំនាក់ទំនងហិរញ្ញវត្ថុរបស់រដ្ឋជាមួយនឹងធនាគារជាតិនៃកម្ពុជា

ដូចមាននៅក្នុងតារាងខាងក្រោមនេះ ÷

| តារាងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស (+) ឱនភាព (−) |
|---|---|---|
| ១/- ចំណូលក្នុងប្រទេស | ៨៨១ ០០៧ | |
| ១.១-ចំណូលក្នុងប្រទេសជាប្រចាំ | ៨៦៨ ៦៧២ | |
| ១.២-ចំណូលក្នុងប្រទេសជាមូលធន | ១២ ៣៣៥ | |
| ២/- ចំណាយថវិកា | ១ ២៦៧ ៩២១ | |
| ២.១-ចំណាយជាប្រចាំ | ៨១៥ ៩៨២ | |
| ២.២-ចំណាយជាមូលធន [២] ក្នុងនោះ: | ៤៥១ ៩៣៩ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ១១០ ៣២២ | |
| - - ដោយមូលនិធិថវិកា | ៩៥ ៨៣៥ | |
| +គំរោងវិនិយោគ (សាងសង់, ទិញសម្ភារៈ) | ៧៨ ៥២៤ | |
| +ចំណាយក្នុងប្រទេសលើវិនិយោគដោយហិរញ្ញប្បទានបរទេស (បដិភាគ) | ១៧ ៣១១ | |
| - ដោយមូលនិធិបរទេស | ១៤ ៤៨៧ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ (ជំនួយគំរោងការ) | ៣៤១ ៦១៧ | |
| ចំនួនលើសនៃថវិកាជាប្រចាំ | | (+) ៦០ ៨៥៨ [៣] |
| ឱនភាពនៃថវិកាទូទៅ | | (−) ៣៧៨ ៧៤៦ |
| ៣/- ហិរញ្ញប្បទាននៃឱនភាព | | ៣៧៨ ៧៤៦ |
| ៣.១- ហិរញ្ញប្បទានពីបរទេស | | ៤៤៩ ៨៧៣ |
| - ជំនួយគាំទ្រថវិកាមិនមានកំណត់មុខសញ្ញាចំណាយ | | ២០ ៥៨៥ |
| - ជំនួយគាំទ្រថវិកាមានកំណត់មុខសញ្ញាចំណាយ | | ៧៥ ៣៩៣ |
| - ជំនួយគំរោងការ | | ៣៥០ ៨៣៦ [៤] |
| - ការរំលស់បំណុលបរទេស | | (−)៩៤១ |
| ៣.២- ហិរញ្ញប្បទានក្នុងប្រទេស | | (−) ៦៧ ១២៧ |
| - ហិរញ្ញប្បទានធនាគារ | | (−) ៧៥ ២៧៣ |
| - ការរំលស់បំណុលក្នុងប្រទេស | | (−) ៣ ១០៤ |
| - ប្រាក់បញ្ញើនិងកិច្ចប្រតិបត្តិការផ្សេងៗទៀតនៃរតនាគារ | | ១១ ២៥៣ |

[២] មិនទាន់គិតការរំលស់បំណុល ៤ ៧៥០ លានរៀលទេ ។

[៣] ក្នុងនោះមានកំណែតំរូវជាវិជ្ជមាននៃចំណាយចំនួន (+) ៥ ១៦៨ លានរៀល ។

[៤] ក្នុងនោះមានទឹកប្រាក់ចំនួន ៩ ២២០ លានរៀល ត្រូវរង់ចាំការប្រើប្រាស់។

# ជំពូកទី៥

## អវសានប្បញ្ញត្តិ

មាត្រា ៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែកក្កដា ឆ្នាំ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋ ស្ដីទី

ហត្ថលេខា

ជា ស៊ីម

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ: [illegible] ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ១៩៩៩

អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

[illegible] កេន